# សម្លាប់ស្នេហបង ចង់ឱយបេះដូងបងរស់

អូនពេញចិត្តទេ? បើរូបបង

រីករាយកន្លង ពេលស្នេហាចប់

អាចញញឹមបាន គ្មានធុញថប់

ថែមគ្មានចិត្តស្អប់ ប្រកាន់ខឹង។

អូនសាកដាក់ចិត្ត បងលោមើល

បងមិនអើពើ នឹងព្រលឹង

សម្លាប់ស្នេហអូន ដោយកំហឹង

មាសមេនឹងដឹង ថារីករាយ!។

រីករាយព្រោះមាន ឱកាសថ្មី

អាចតាមរកស្រី ថ្មីដោយងាយ

ក្រែងអាចល្អជាង ទាំងទ្រង់ទាយ

ចរិតមិនស្អាយ ទុក្ខដូចស្រី។

គួរឱយស្តាយណាស់! ព្រោះរូបបង

មិនមែនទួនល្អង រស់ប្រពៃ

អាចមានប្រុសថ្មី គួរបេតី

ជាងបងគ្មានអ្វី ល្អសមពៅ។

ក្រោយបាត់បង់អូន ស្នេហបងឈឺ

និយាយមិនឮ ដើរតាមផ្លូវ

ស្រែកហៅរកស្នេហ ដែលឆ្ងាយទៅ

មិនឃើញអូននៅ ក៏ចាំស្រី។

បើជ្រុលដាច់ចិត្ត សម្លាប់វា

តើស្រស់ពំងា ខ្វាយខ្វល់អ្វី?

ចាំបាច់ពោលពាក្យ សំណាងថ្មី

សំណាងពិសី បោះបង់ឬ?

បើសម្រាប់អូន ពិតសំណាង

អ្នកថ្មីស្រឡាង ចាំងពន្លឺ

ឱយតម្លៃអូន ជាងបងគឺ

គ្រប់គ្នាដឹងឮ សូម្បីបង។

ដូច្នេះហើយទើប អូនសម្លាប់

ស្នេហបងឱយស្លាប់ ហើយស្នេហស្នង

បង្រស់ស្នេហាគេនិងនួនល្អង

ពាក្យដាច់កន្លង មិនដែលស្នេហ។

តែក្រោយស្នេហស្លាប់ ចង់ឱយបង

កាត់ចិត្តចំណង រួចកែប្រែ

ចិត្តឱយរីករាយ ដូចអូនដែរ

ទាំង**សាកសពស្នេហ** មិនទាន់ក្រៀម។

ទោះសាកសពស្នេហ អាចទ្រាំបាន

ចិត្តបងកល្យាណ ឆេះខ្លោចឈ្លៀម!

មិនដឹងថាជា យូរឬភ្លាម

ឬស្លាប់គ្មានឈាម លែងរស់វិញ។

ដូចអូនមិនមាន ឈើបន្តិច

សុខចាក់មិនលិច គ្មានទោម្ទេញ

អាចសាងស្នេហាថ្មី រីករាយពេញ

អាចវាចាចេញ អួតគេឯង។

អូនមិនបាច់ធ្វើ ល្អនោះទេ

ព្រោះស្រស់មាសមេ ល្អជាក់ស្តែង

ល្អទើបរូបបង ខំខ្នះខ្នែង

ចែចង់ប្រឹងប្រែង យកវរមិត្រ។

អូនចង់ឱយបង អាចសប្បាយ

ព្រោះស្រស់ឆោមឆាយ នៅមានចិត្ត

មិនចង់ឱយបង រស់ក្រៀមស្វិត

ព្រោះស្នេហាពិត នៅមានទៀត។

អូននិយាយដូច ងាយខ្លាំងណាស់

ស្នេហស្លាប់មុនចាស់ បងចោលម្សៀត

មិនអាចថែវា ទើបឆាប់ឃ្លាត

សមអូនពិឃាត ស្នេហាបង។

សម្លាប់ស្នេហបង តែចង់ឱយ

បងកុំបណ្តោយ ឱយទុក្ខចង

ព្រោះទុក្ខជា របស់នួនល្អង

ដែលអូនជូនបង ថ្ងៃស្នេហស្លាប់៕

—S. TAY, Fri., 22:48-23:38, 09/11/2012